# សុន្ទរកថាស្វាគមន៍

## ឯកឧត្តម ឡៅ សុខារម្ភ អគ្គលេខាធិការនៃ
## ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
## ថ្លែងក្នុងឱកាសអបអរសាទរ ទិវាជាតិអាហារូបត្ថម្ភ លើកទី៤
## ក្រោមប្រធានបទ "ផលិតនិងបរិភោគអាហារចម្រុះសម្បូរជីវជាតិ ដើម្បីសុខភាពល្អមាំមួន"

*********

- សូមគោរពឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកស្រី **Nancy Walters** អ្នកតំណាងប្រចាំប្រទេសកម្ពុជាអង្គការស្បៀងអាហារពិភពលោក **WFP**
- លោក **Keith Porter** នាយកប្រតិបត្តិអង្គការ ហេលែន ខេលី អន្តរជាតិ ប្រចាំកម្ពុជា
- លោកស្រី **Veena Reddy** នាយិការងបេសកកម្មទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៅកម្ពុជា **USAID**
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តម លោកជំទាវ ប្រធានអង្គការដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជននានា
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ប្អូនៗនិស្សិត និងសមាជិក សមាជិកានៃអង្គពិធីទាំងមូលជាទីមេត្រី !

ថ្ងៃនេះ គឺជាឱកាសដ៏មហានក្ខត្តឫក្ស និងជាទិវាប្រកបដោយសេចក្តីរំភើបរីករាយយ៉ាងក្រៃលែង ដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងក្រុមហ៊ុនទូរសព្ទ័នានា ប្រារព្ធខួប **ទិវាជាតិអាហារូបត្ថម្ភលើកទី៤** (៦វិច្ឆិកា២០១៤-**៦វិច្ឆិកា២០១៧**)ក្រោមប្រធានបទ"**ផលិត និងបរិភោគអាហារចម្រុះសម្បូរជីវជាតិ ដើម្បីសុខភាពល្អមាំមួន**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

យើងខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលមេត្តាជ្រាបថា៖ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចយកថ្ងៃទី៦វិច្ឆិកាជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាជាតិអាហារូបត្ថម្ភ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈឲ្យបានកាន់តែទូលំទូលាយនៅទូទាំងប្រទេស អំពីសារៈសំខាន់នៃអាហារូបត្ថម្ភ ក្នុងការចូលរួមចំណែកបង្កើតមូលធនមនុស្ស បង្កើនផលិតភាពការងារ និងជំរុញកំណើនសេដ្ឋកិច្ច។ **អាហារូបត្ថម្ភជាបញ្ហាអន្តរៈវិស័យ** អាស្រ័យហេតុនេះ ទិវាជាតិអាហារូបត្ថម្ភតែងតែជ្រើសរើសប្រធានបទទៅតាមវិស័យនិមួយៗស្របតាមស្ថានភាពជាក់ស្តែង ។

- ទិវាជាតិអាហារូបត្ថម្ភលើកទី១បានប្រារព្ធនៅថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ២០១៤ក្រោមប្រធានបទ "**អាហារូបត្ថម្ភល្អ ដើម្បីជីវិតរស់នៅកាន់តែប្រសើរ**"។
- ទិវាជាតិអាហារូបត្ថម្ភលើកទី២ បានប្រារព្ធនៅថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ២០១៥ ក្រោមប្រធានបទ"**ការចំណីកូនដោយទឹកដោះម្ដាយគឺជាការវិនិយោគដ៏ប្រសើរបំផុតសម្រាប់ជីវិតកូនអ្នក**"។
- ទិវាជាតិអាហារូបត្ថម្ភលើកទី៣ បានប្រារព្ធនៅថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ២០១៦ ក្រោមប្រធានបទ"**អនាម័យ និងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ**" ។
- ថ្ងៃនេះ យើងជួបជុំគ្នាដើម្បីប្រារព្ធ**ទិវាជាតិអាហារូបត្ថម្ភលើកទី៤** ក្រោមប្រធានបទ"**ផលិត និងបរិភោគអាហារចម្រុះសម្បូរជីវជាតិ ដើម្បីសុខភាពល្អមាំមួន**"។

ស្ថិតក្នុងបរិយាកាសដ៏មហោឡារិកនេះ យើងខ្ញុំមានកិត្តិយសសូមស្វាគមន៍ដ៏ខ្ពង់ខ្ពស់និងកក់ក្ដៅបំផុត និងសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះវត្តមាន ដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ-អន្តរជាតិ មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ដែលបានចំណាយពេលវេលាដ៏មានតម្លៃនិងមមាញឹកអញ្ជើញចូលរួមក្នុងអង្គពិធីដ៏មានសារៈសំខាន់ នាពេលនេះ។

ជំនួសមុខឲ្យអង្គពិធីទាំងមូល ខ្ញុំសូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការ USAID, UNICEF, FAO, WFP, GIZ និងបណ្ដាញអង្គការសង្គមស៊ីវិលដែលដឹកនាំដោយអង្គការ Helen Keller International, ដែលបានសហការរៀបចំនិងឧបត្ថម្ភដល់ **ទិវាជាតិអាហារូបត្ថម្ភលើកទី៤** នេះ។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណ ដល់ក្រុមហ៊ុនទូរសព្ទ័ Mobitel, ក្រុមហ៊ុន MetFone និងក្រុមហ៊ុន Smart ដែលបានជួយផ្សព្វផ្សាយ តាមរយៈការបញ្ជូនសារទៅកាន់ទូរសព្ទ័ដៃរបស់អតិថិជនរបស់ខ្លួននៅទូទាំងប្រទេស នូវពាក្យស្លោកសំខាន់ៗ របស់ទិវាជាតិអាហារូបត្ថម្ភ ក្នុងគោលបំណងអប់រំ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការចូលរួមចំណែកលើកកម្ពស់អាហារូបត្ថម្ភ ។ ពាក្យស្លោកទាំងនោះរួមមាន៖

1. ផ្ដល់បន្លែ ផ្លែឈើ ត្រី សាច់ និង ស៊ុតដល់កុមារពីអាយុ ៦ខែ ឡើងដើម្បីការលូតលាស់ល្អ
2. បរិភោគអាហារចំរុះ បន្លែ ផ្លែឈើ ត្រី សាច់ និងស៊ុត ដើម្បីគ្រួសារមានសុខភាពល្អ
3. ដាំបន្លែ ផ្លែឈើ តាមផ្ទះ សហគមន៍និងសាលារៀន ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ

ដើម្បីឲ្យអង្គពិធីទាំងមូលយល់ជ្រាបច្បាស់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់អាហារូបត្ថម្ភ**ដែលជាចលករនៃការអភិវឌ្ឍប្រកបដោយចិរភាព** ខ្ញុំបាទសូមអានសារលិខិតសម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងឱកាសទិវាជាតិអាហារូបត្ថម្ភ លើកទី៤ ក្រោមប្រធានបទ "**ផលិត និងបរិភោគអាហារចម្រុះសម្បូរជីវជាតិ ដើម្បីសុខភាពល្អមាំមួន**" ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖ (*អានសារសម្ដេច*)